ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាភូមិន្ទរដ្ឋបាល

វិន័យ គុណភាព គុណធម៌ នវានុវត្តន៍

សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣

# កិច្ចការស្រាវជ្រាវ

## ស្តីពីគម្រោង

# ការដាក់ផ្លាកលេខផ្ទះ និងផ្លាកលេខផ្លូវ

**មុខវិជ្ជា** ៖ ការគ្រប់គ្រងគម្រោង

**ឧទ្ទេសនាមដោយ** ៖ បណ្ឌិត ព្រុំ ទេវី

**ស្រាវជ្រាវដោយ** ៖ សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣ ក្រុមទី៤

១- លោក សំ ស៊ីនួន

២- លោក ហេង ស្រេង

៣- លោក អ៊ិត ហង្សា

៤- លោក អ៊ុច វណ្ណថេត

៥- លោក ហាត់ បូសើង

ឆ្នាំសិក្សា ២០២៥ - ២០២៧

## ១. សាវតាគម្រោង

គម្រោងកាផ្លាកលេខផ្លូវ និងផ្លាកលេខផ្ទះ ជូនដល់ប្រជាពលរដ្ឋនៅភូមិស្ពុះ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ គឺជាការចូលរួមចំណែកក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន ដើម្បីលើកម្ពស់សោភណ្ឌភាព ក្នុងការស្វែងរកអាសយដ្ឋាន ដែលមានទីតាំងសម្គាល់ច្បាស់លាស់ និងងាយស្រួលសម្រាប់ផ្តល់ សេវាសាធារណៈ និងការគ្រប់គ្រងទិន្នន័យប្រជាសាស្ត្រនៅក្នុងតំបន់បានកាន់តែល្អប្រសើរ។

## ២. ផែនការគម្រោង

### ២.១. គោលបំណង

គម្រោងការងារសង្គមរបស់សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣ ក្រោមប្រធានបទ "**ការដាក់អំពូលសូឡាបំភ្លឺផ្លូវ ផ្លាកលេខផ្ទះ និងផ្លាកលេខផ្លូវ**" មានគោលបំណង **ធ្វើឱ្យកាន់តែប្រសើរឡើងនូវការផ្តល់សេវាសាធារណៈ និងលើកកម្ពស់គុណភាពជីវិតរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។**

### ២.២. គោលដៅ

ដើម្បីជានាសម្រេចបានជោគជ័យនូវលទ្ធផលឆ្លើយតបទៅនឹងគោលបំណងដ៏មានសារៈសំខាន់ខាងលើ គោលដៅអាទិភាពចំនួន៣ ត្រូវបានដាក់ចេញសម្រាប់អនុវត្ត ដែលរួមមានដូចខាងក្រោម៖

**គោលដៅទី១៖** ការកំណត់អំពីសកម្មភាពការងារ និងបង្កើតយន្តការ (ក្រុមការងារ) ចាំបាច់ក្នុងការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការអនុវត្តការងារ។

**គោលដៅទី២៖** ចាប់ផ្តើមដំណើរការការងាររបស់ក្រុមការងារនីមួយៗ និងអនុវត្តសកម្មភាពការងារស្របតាមផែនការសកម្មភាពដែលបានរៀបចំ។

**គោលដៅទី៣៖** ដាក់ឱ្យប្រជាពលរដ្ឋ និងអាជ្ញាធរនៅមូលដ្ឋានប្រើប្រាស់ជាផ្លូវការ និងបង្ហាញអំពីរបៀបប្រើប្រាស់ សារៈសំខាន់ និងតម្លៃនៃការដាក់ផ្លាកលេខផ្ទះ និងផ្លូវ។

### ២.៣. សកម្មភាព

ដើម្បីសម្រេចបានគោលដៅទាំង៣ នៃគម្រោងខាងលើ ក្រុមការងារបានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

*គោលដៅទី១៖ ការកំណត់អំពីសកម្មភាពការងារ និងបង្កើតយន្តការ (ក្រុមការងារ) ចាំបាច់ ក្នុងការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការអនុវត្តការងារ។*

**សកម្មភាពទី១.១៖** ការចូលរួមក្នុងកិច្ចប្រជុំជាមួយគណៈគ្រប់គ្រងនៃសាលាភូមិន្ទរដ្ឋបាល ដើម្បីទទួលការណែនាំតម្រង់ទិសអំពីការអនុវត្តការងារសង្គម និងធ្វើទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានដើម្បីកំណត់បាននូវសកម្មភាព និងតម្រូវការដាក់លាក់របស់ប្រជាពលរដ្ឋ។

**សកម្មភាពទី១.២៖** រៀបចំបង្កើតគណៈកម្មការដឹកនាំការអនុវត្តការងារសង្គម របស់សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣ និងក្រុមការងារចាំបាច់នានាចំណុះគណកម្មការ ជាយន្តការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលក្នុងដំណើរការអនុវត្តការងារសង្គម។ ជាមួយគ្នានេះផងដែរ ក៏ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី ភារកិច្ចរបស់គណៈកម្មការ និងក្រុមការងារនីមួយៗ ដើម្បីធានាដល់ប្រសិទ្ធភាព និងសម្រេចបាននូវលទ្ធផលតាមផែនការ។

**សកម្មភាពទី១.៣៖** ផែនការសកម្មភាព និងថវិកា នឹងត្រូវបានរៀបចំដើម្បីគាំទ្រ និងតាមដានទៅលើដំណើរការការអនុវត្តការងារសង្គម។ ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន ក្រុមការងារទាំងអស់ចំណុះគណៈកម្មការត្រូវសហការរៀបចំតាក់តែងផែនការសកម្មភាព និងថវិការបស់ខ្លួន ដើម្បីជាមូលដ្ឋានក្នុងការរៀបចំ និងដាក់ចេញនូវផែនការសកម្មភាព និងថវិកា ដែលនឹងត្រូវអនុម័តដោយគណៈកម្មការ។

*គោលដៅទី២៖ ចាប់ផ្តើមដំណើរការការងាររបស់ក្រុមការងារនីមួយៗ និងអនុវត្តសកម្មភាពការងារស្របតាមផែនការសកម្មភាពដែលបានរៀបចំ។*

**សកម្មភាពទី២.១៖** បង្កើតមូលនិធិសម្រាប់ចំណាយអនុវត្តការងារសង្គមរបស់សិស្សមន្ត្រីជាន់ខ្ពស់ សម្រាប់ប្រមូល គ្រប់គ្រង និងចាត់ចែងការប្រើប្រាស់ថវិកាសម្រាប់ចំណាយនៅគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោង។

**សកម្មភាពទី២.២៖** ក្រុមការងារបច្ចេកទេស ត្រូវដឹកនាំអនុវត្តការងារលើផ្នែកបច្ចេកទេសចាំបាច់លើការកំណត់ទីតាំងភូមិសាស្ត្រ និងទិន្នន័យលើផ្លាកលេខផ្ទះនិងផ្លូវ។

**សកម្មភាពទី២.៣៖** រៀបចំបោះពុម្ពផ្លាកលេខផ្ទះ និងផ្លាកលេខផ្លូវ និងបង្គោលអំពូលឡាលសូឡាបំភ្លឺផ្លូវ សម្រាប់ដាក់ជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។

*គោលដៅទី៣៖ ដាក់ឱ្យប្រជាពលរដ្ឋ និងអាជ្ញាធរនៅមូលដ្ឋានប្រើប្រាស់ជាផ្លូវការ និងបង្ហាញអំពីរបៀបប្រើប្រាស់ សារៈសំខាន់ និងតម្លៃនៃការដាក់ផ្លាកលេខផ្ទះ និងផ្លូវ។*

**សកម្មភាពទី៣.១៖** រៀបចំកម្មវិធីប្រគល់ និងសម្ពោធដាក់ឱ្យប្រើប្រាស់នូវសមិទ្ធផលដែលសម្រេចបានជូនអាជ្ញាធរ និងប្រជាពលរដ្ឋនៅមូលដ្ឋាន។

**សកម្មភាពទី៣.២៖** ធ្វើការបូកសរុបទៅលើការចំណាយក្នុងការអនុវត្តការងារសង្គម។

**សកម្មភាពទី៣.៣៖** ធ្វើការបូកសរុប និងវាយតម្លៃលើការអនុវត្តគម្រោងទាំងមូល។

### ២.៥. សូចនាករ

ដើម្បីសម្រេចបានគោលដៅ និងការអនុវត្តនៃសកម្មភាពនីមួយៗ ប្រកបដោយភាពជោគជ័យ និង មានប្រសិទ្ធភាពខ្ពស់សម្រាប់ធ្វើការរៀបចំគម្រោងខាងលើ ក្រុមការងារបានកំណត់នូវសូចនាករសំខាន់ៗ ដូចជា៖

*គោលដៅទី១៖ ការកំណត់អំពីសកម្មភាពការងារ និងបង្កើតយន្តការ (ក្រុមការងារ) ចាំបាច់ ក្នុងការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការអនុវត្តការងារ។*

**សកម្មភាព ១.១.៖** ការចូលរួមក្នុងកិច្ចប្រជុំជាមួយគណៈគ្រប់គ្រងនៃសាលាភូមិន្ទរដ្ឋបាល ដើម្បីទទួលការណែនាំតម្រង់ទិសអំពីការអនុវត្តការងារសង្គម និងធ្វើទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានដើម្បីកំណត់បាននូវសកម្មភាព និងតម្រូវការជាក់លាក់របស់ប្រជាពលរដ្ឋ។

*សូចនាករ ១.១.១.៖ ផែនការសកម្មភាពលម្អិតសម្រាប់ការងារសង្គម ដែលត្រូវបានរៀបចំឡើងដោយផ្អែកលើការណែនាំរបស់គណៈគ្រប់គ្រងសាលា និងការឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានគោលដៅ។*

**សកម្មភាព ១.២.៖** រៀបចំបង្កើតគណៈកម្មការដឹកនាំការអនុវត្តការងារសង្គម របស់សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣ និងក្រុមការងារចាំបាច់នានាចំណុះគណកម្មការ ជាយន្តការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលក្នុងដំណើរការអនុវត្តការងារសង្គម។ ជាមួយគ្នានេះផងដែរ ក៏ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី ភារកិច្ចរបស់គណៈកម្មការ និងក្រុមការងារនីមួយៗ ដើម្បីធានាដល់ប្រសិទ្ធភាព និងសម្រេចបាននូវលទ្ធផលតាមផែនការ។

*សូចនាករ ១.២.១.៖ សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការដឹកនាំ និងក្រុមការងារនានាត្រូវបានរៀបចំ និងចុះហត្ថលេខាប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ។ គណៈកម្មការ និងក្រុមការងារទាំងអស់មានលិខិតបង្គាប់ការដែលកំណត់ច្បាស់លាស់នូវតួនាទី ភារកិច្ច និងរបៀបរបបការងារ ដើម្បីធានាបាននូវការដឹកនាំ និងសម្របសម្រួលការងារសង្គមឱ្យមានសណ្ដាប់ធ្នាប់។*

**សកម្មភាព ១.៣.៖** ផែនការសកម្មភាព និងថវិកា នឹងត្រូវបានរៀបចំដើម្បីគាំទ្រ និងតាមដានទៅលើដំណើរការការអនុវត្តការងារសង្គម។ ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន ក្រុមការងារទាំងអស់ចំណុះគណៈកម្មការត្រូវសហការរៀបចំតាក់តែងផែនការសកម្មភាព និងថវិការបស់ខ្លួន ដើម្បីជាមូលដ្ឋានក្នុងការរៀបចំ និងដាក់ចេញនូវផែនការសកម្មភាព និងថវិកា ដែលនឹងត្រូវអនុម័តដោយគណៈកម្មការ។

*សូចនាករ ១.៣.១.៖ ផែនការសកម្មភាព និងថវិកាដែលត្រូវបានអនុម័ត មានកំណត់ច្បាស់លាស់នូវប្រភពចំណូល ការចំណាយតាមមុខសញ្ញា និងតារាងពេលវេលាអនុវត្តការងារ (Work Plan)។*

*គោលដៅទី២៖ ចាប់ផ្ដើមដំណើរការការងាររបស់ក្រុមការងារនីមួយៗ និងអនុវត្តសកម្មភាពការងារស្របតាមផែនការសកម្មភាពដែលបានរៀបចំ។*

**សកម្មភាព ២.១.៖** បង្កើតមូលនិធិសម្រាប់ចំណាយអនុវត្តការងារសង្គមរបស់សិស្សមន្ត្រីជាន់ខ្ពស់ សម្រាប់ប្រមូល គ្រប់គ្រង និងចាត់ចែងការប្រើប្រាស់ថវិកាសម្រាប់ចំណាយនៅគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោង។

*សូចនាករ ២.១.១៖ មូលនិធិការងារសង្គមត្រូវបានបង្កើតឡើង និងទទួលបានការចូលរួមបដិភាគថវិកាគ្រប់ចំនួនតាមការកំណត់ក្នុងផែនការ ឬលើសពីការរំពឹងទុក ដើម្បីធានាដល់ការអនុវត្តសកម្មភាពទាំងស្រុង។*

**សកម្មភាព ២.២.៖** ក្រុមការងារបច្ចេកទេស ត្រូវដឹកនាំអនុវត្តការងារលើផ្នែកបច្ចេកទេសចាំបាច់លើការកំណត់ទីតាំងភូមិសាស្ត្រ និងទិន្នន័យលើផ្លាកលេខផ្ទះនិងផ្លូវ។

*សូចនាករ ២.២.១៖ មូលដ្ឋានទិន្នន័យ (Database) នៃប្រព័ន្ធលេខផ្ទះ និងឈ្មោះផ្លូវ ត្រូវបានរៀបចំឡើងយ៉ាងច្បាស់លាស់ ដោយមានផែនទីបង្ហាញទីតាំងភូមិសាស្ត្រ (GIS Mapping) ងាយស្រួលក្នុងការគ្រប់គ្រង និងស្វែងរក។*

**សកម្មភាព ២.៣.៖** រៀបចំបោះពុម្ពផ្លាកលេខផ្ទះ និងផ្លាកលេខផ្លូវ និងបង្គោលអំពូឡាលសូឡាបំភ្លឺផ្លូវ សម្រាប់ដាក់ជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។

*សូចនាករ ២.៣.១៖ ចំនួនផ្លាកលេខផ្ទះ ផ្លាកឈ្មោះផ្លូវ និងបង្គោលអំពូលសូឡាបំភ្លឺផ្លូវ ត្រូវបានបោះពុម្ព និងផលិតរួចរាល់គ្រប់ចំនួនតាមតម្រូវការដែលបានកំណត់ ក្នុងគុណភាពស្របតាមស្តង់ដារបច្ចេកទេស។*

*គោលដៅទី៣៖ ដាក់ឱ្យប្រជាពលរដ្ឋ និងអាជ្ញាធរនៅមូលដ្ឋានប្រើប្រាស់ជាផ្លូវការ និងបង្ហាញអំពីរបៀបប្រើប្រាស់ សារៈសំខាន់ និងតម្លៃនៃការដាក់ផ្លាកលេខផ្ទះ និងផ្លូវ។*

**សកម្មភាព ៣.១.៖** រៀបចំកម្មវិធីប្រគល់ និងសម្ពោធដាក់ឱ្យប្រើប្រាស់នូវសមិទ្ធផលដែលសម្រេចបានជូនអាជ្ញាធរ និងប្រជាពលរដ្ឋនៅមូលដ្ឋាន។

*សូចនាករ ៣.១.១៖ កម្មវិធីប្រគល់ និងសម្ពោធដាក់ឱ្យប្រើប្រាស់សមិទ្ធផលការងារសង្គមត្រូវបានរៀបចំឡើងដោយជោគជ័យ ក្រោមអធិបតីភាពគណៈគ្រប់គ្រងសាលា អាជ្ញាធរដែនដី និងមានការចូលរួមពីប្រជាពលរដ្ឋយ៉ាងច្រើនកុះករ។*

**សកម្មភាព ៣.២.៖** ធ្វើការបូកសរុប និងវាយតម្លៃទៅលើការចំណាយសរុបការដែលប្រើប្រាស់នៅក្នុងដំណើរការអនុវត្តគម្រោងការងារសង្គម។

*សូចនាករ ៣.២.១៖ របាយការណ៍បូកសរុបការចំណាយ ត្រូវបានផ្សព្វផ្សាយ និងបញ្ជាក់ជូនសមាជិកក្រុមការងារសិស្សមន្ត្រី និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីបញ្ចប់ការទទួលខុសត្រូវលើមូលនិធិការងារសង្គម។*

**សកម្មភាព ៣.៣.៖** ធ្វើការបូកសរុប និងវាយតម្លៃលើលទ្ធផលនៃដំណើរការការអនុវត្តគម្រោងការងារសង្គមទាំងមូល។

*សូចនាករ ៣.៣.១៖ របាយការណ៍បូកសរុបលទ្ធផលការងារចុងក្រោយ (Final Completion Report) ត្រូវបានរៀបចំឡើងយ៉ាងគ្រប់ជ្រុងជ្រោយ ដែលបង្ហាញពីសមិទ្ធផលសម្រេចបានធៀបនឹងគោលដៅរំពឹងទុក និងមេរៀនដែលទទួលបានពីការអនុវត្តគម្រោង។*

## ២.៦. មធ្យោបាយផ្ទៀងផ្ទាត់

ដោគជ័យ ដើម្បីសម្រេចបានគោលដៅ និងការអនុវត្តនៃព ងការអនុវត្តនៃសកម្មភាពនីមួយៗ និងមានប្រសិទ្ធភាពខ្ពស់សម្រាប់ធ្វើការរៀបចំគម្រោងខាងលើ មធ្យោបាយផ្ទៀងផ្ទាត់សំខាន់ៗដូចខាងក្រោមៈ ប្រកបដោយភាព ក្រុមការបានប្រើ

*គោលដៅទី១ៈ ការកំណត់អំពីសកម្មភាពការងារ និងបង្កើតយន្តការ (ក្រុមការងារ) ចាំបាច់ ក្នុងការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការអនុវត្តការងារ។*

**សកម្មភាព ១.១.ៈ** ការចូលរួមក្នុងកិច្ចប្រជុំជាមួយគណៈគ្រប់គ្រងនៃសាលាភូមិន្ទរដ្ឋបាល ដើម្បីទទួលការណែនាំតម្រង់ទិសអំពីការអនុវត្តការងារសង្គម និងធ្វើទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានដើម្បីកំណត់បាននូវសកម្មភាព និងតម្រូវការជាក់លាក់របស់ប្រជាពលរដ្ឋ។

*មធ្យោបាយផ្ទៀងផ្ទាត់ ១.១.១.ៈ ឯកសារកត់ត្រាខ្លឹមសារនៃការណែនាំពីគណៈគ្រប់គ្រងសាលាភូមិន្ទរដ្ឋបាល និងលទ្ធផលនៃជំនួបជាមួយអាជ្ញាធរមូលដ្ឋាន។*

**សកម្មភាព ១.២.ៈ** រៀបចំបង្កើតគណៈកម្មការដឹកនាំការអនុវត្តការងារសង្គម របស់សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣ និងក្រុមការងារចាំបាច់នានាចំណុះគណកម្មការ ជាយន្តការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលក្នុងដំណើរការអនុវត្តការងារសង្គម។ ជាមួយគ្នានេះផងដែរ ក៏ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី ភារកិច្ចរបស់គណៈកម្មការ និងក្រុមការងារនីមួយៗ ដើម្បីធានាដល់ប្រសិទ្ធភាព និងសម្រេចបាននូវលទ្ធផលតាមផែនការ។

*មធ្យោបាយផ្ទៀងផ្ទាត់ ១.២.១.ៈ ឯកសារលម្អិតដែលចែងពីការទទួលខុសត្រូវរបស់គណៈកម្មការដឹកនាំ និងក្រុមការងារបច្ចេកទេសនានា (ឧទាហរណ៍ៈ ក្រុមបច្ចេកទេស ក្រុមហិរញ្ញវត្ថុ ក្រុមទំនាក់ទំនង...)។*

**សកម្មភាព ១.៣.ៈ** ផែនការសកម្មភាព និងថវិកា នឹងត្រូវបានរៀបចំដើម្បីគាំទ្រ និងតាមដានទៅលើដំណើរការការអនុវត្តការងារសង្គម។ ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន ក្រុមការងារទាំងអស់ចំណុះគណៈកម្មការត្រូវសហការរៀបចំតាក់តែងផែនការសកម្មភាព និងថវិការបស់ខ្លួន ដើម្បីជាមូលដ្ឋានក្នុងការរៀបចំ និងដាក់ចេញនូវផែនការសកម្មភាព និងថវិកា ដែលនឹងត្រូវអនុម័តដោយគណៈកម្មការ។

*មធ្យោបាយផ្ទៀងផ្ទាត់ ១.៣១.ៈ ឯកសារផែនការសកម្មភាពលម្អិតដែលមានបញ្ជាក់ពីលំដាប់លំដោយនៃសកម្មភាព កាលបរិច្ឆេទអនុវត្ត និងអ្នកទទួលខុសត្រូវតាមផ្នែកនីមួយៗ។*

*គោលដៅទី២ៈ ចាប់ផ្ដើមដំណើរការការងាររបស់ក្រុមការងារនីមួយៗ និងអនុវត្តសកម្មភាពការងារស្របតាមផែនការសកម្មភាពដែលបានរៀបចំ។*

**សកម្មភាពទី២.១.៖** បង្កើតមូលនិធិសម្រាប់ចំណាយអនុវត្តការងារសង្គមរបស់សិស្សមន្ត្រីជាន់ខ្ពស់ សម្រាប់ប្រមូល គ្រប់គ្រង និងចាត់ចែងការប្រើប្រាស់ថវិកាសម្រាប់ចំណាយនៅគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោង។

*មធ្យោបាយផ្ទៀងផ្ទាត់ ២.១.១.៖ សេចក្ដីសម្រេចស្ដីពីការបង្កើតមូលនិធិ និងឯកសារផ្លូវការដែលបញ្ជាក់ពីការបង្កើតមូលនិធិ និងរចនាសម្ព័ន្ធគ្រប់គ្រង។*

**សកម្មភាពទី២.២.៖** ក្រុមការងារបច្ចេកទេស ត្រូវដឹកនាំអនុវត្តការងារលើផ្នែកបច្ចេកទេសចាំបាច់លើការកំណត់ទីតាំងភូមិសាស្ត្រ និងទិន្នន័យលើផ្លាកលេខផ្ទះនិងផ្លូវ។

*មធ្យោបាយផ្ទៀងផ្ទាត់ ២.២.១.៖ របាយការណ៍លទ្ធផលនៃការចុះអង្កេត និងកំណត់ទីតាំង (Field Survey Report), ឯកសារដែលបង្ហាញពីសកម្មភាពចុះវាស់វែង និងកំណត់និយាមកាទីតាំងជាក់ស្ដែង។*

**សកម្មភាពទី២.៣.៖** រៀបចំបោះពុម្ពផ្លាកលេខផ្ទះ និងផ្លាកលេខផ្លូវ និងបង្គោលអំពូលសូឡាបំភ្លឺផ្លូវ សម្រាប់ដាក់ជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។

*មធ្យោបាយផ្ទៀងផ្ទាត់ ២.៣.១.៖ កំណត់ហេតុទទួលសម្ភារ (Delivery Note/Receiving Report), ឯកសារបញ្ជាក់ថា សម្ភារ (ផ្លាកលេខផ្ទះ ផ្លាកផ្លូវ និងបង្គោលសូឡា) ត្រូវបានផលិត និងដឹកជញ្ជូនមកដល់កន្លែងស្តុកទុកគ្រប់ចំនួន។*

*គោលដៅទី៣៖ ដាក់ឱ្យប្រជាពលរដ្ឋ និងអាជ្ញាធរនៅមូលដ្ឋានប្រើប្រាស់ជាផ្លូវការ និងបង្ហាញអំពីរបៀបប្រើប្រាស់ សារៈសំខាន់ និងតម្លៃនៃការដាក់ផ្លាកលេខផ្ទះ និងផ្លូវ។*

**សកម្មភាព ៣.១.៖** រៀបចំកម្មវិធីប្រគល់ និងសម្ពោធដាក់ឱ្យប្រើប្រាស់នូវសមិទ្ធផលដែលសម្រេចបានជូនអាជ្ញាធរ និងប្រជាពលរដ្ឋនៅមូលដ្ឋាន។

*មធ្យោបាយផ្ទៀងផ្ទាត់ទី១៖ របាយការណ៍បូកសរុបលទ្ធផល និងរូបភាពសកម្មភាពនៃកម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ព្រមទាំងបញ្ជីវត្តមានរបស់អ្នកចូលរួម។*

**សកម្មភាព ៣.២.៖** ធ្វើការបូកសរុប និងវាយតម្លៃទៅលើការចំណាយសរុបការដែលប្រើប្រាស់នៅក្នុងដំណើរការអនុវត្តគម្រោងការងារសង្គម។

*មធ្យោបាយផ្ទៀងផ្ទាត់ ៣.២.១.៖ របាយការណ៍ហិរញ្ញវត្ថុបូកសរុបបញ្ចប់គម្រោង ដែលបង្ហាញពីតារាងចំណូល-ចំណាយជាក់ស្ដែង ធៀបនឹងផែនការថវិកាដែលបានគ្រោងទុក។*

**សកម្មភាព ៣.៣.៖** ធ្វើការបូកសរុប និងវាយតម្លៃលើលទ្ធផលនៃដំណើរការការអនុវត្តគម្រោងការងារសង្គមទាំងមូល។

*មធ្យោបាយផ្ទៀងផ្ទាត់ ៣.៣.១.៖ របាយការណ៍បូកសរុបលទ្ធផលការងារ (Final Project Report) ដែលបង្ហាញពីការសម្រេចបាននូវសូចនាករគោលដៅ បញ្ហាប្រឈម និងមេរៀនដែលទទួលបានពីការអនុវត្តគម្រោង។*

## ២.៧. ហានិភ័យ

ដើម្បីសម្រេចបានគោលដៅ និងការអនុវត្តនៃសកម្មភាពនីមួយៗ ប្រកបដោយភាពជោគជ័យ និង មានប្រសិទ្ធភាពខ្ពស់សម្រាប់ធ្វើការរៀបចំគម្រោងខាងលើ ក្រុមការងារបានកំណត់នូវសូចនាករ សំខាន់ៗដូចជា៖

*គោលដៅទី១៖ ការកំណត់អំពីសកម្មភាពការងារ និងបង្កើតយន្តការ (ក្រុមការងារ) ចាំបាច់ ក្នុងការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការអនុវត្តការងារ។*

**សកម្មភាព ១.១.៖** ការចូលរួមក្នុងកិច្ចប្រជុំជាមួយគណៈគ្រប់គ្រងនៃសាលាភូមិន្ទរដ្ឋបាល ដើម្បីទទួលការណែនាំតម្រង់ទិសអំពីការអនុវត្តការងារសង្គម និងធ្វើទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានដើម្បីកំណត់បាននូវសកម្មភាព និងតម្រូវការជាក់លាក់របស់ប្រជាពលរដ្ឋ។

*ហានិភ័យ១.១.១៖ ការទទួលបានការណែនាំតម្រង់ទិសពីសាលាមិនបានទាន់ពេលវេលា ឬមានការផ្លាស់ប្តូរគោលការណ៍ណែនាំភ្លាមៗ ដែលនាំឱ្យប៉ះពាល់ដល់ការរៀបចំផែនការសកម្មភាពដំបូង។*

**សកម្មភាព ១.២.៖** រៀបចំបង្កើតគណៈកម្មការដឹកនាំការអនុវត្តការងារសង្គម របស់សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣ និងក្រុមការងារចាំបាច់នានាចំណុះគណកម្មការ ជាយន្តការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលក្នុងដំណើរការអនុវត្តការងារសង្គម។ ជាមួយគ្នានេះផងដែរ ក៏ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី ភារកិច្ចរបស់គណៈកម្មការ និងក្រុមការងារនីមួយៗ ដើម្បីធានាដល់ប្រសិទ្ធភាព និងសម្រេចបាននូវលទ្ធផលតាមផែនការ។

*ហានិភ័យ ១.២.១៖ ការកំណត់សមាជិកក្នុងគណៈកម្មការ និងក្រុមការងារ មិនមានតុល្យភាពរវាងសមត្ថភាពបច្ចេកទេស និងចំនួនការងារជាក់ស្តែង ដែលនាំឱ្យមានការកកស្ទះការងារក្នុងផ្នែកណាមួយ។*

**សកម្មភាព ១.៣.៖** ផែនការសកម្មភាព និងថវិកា នឹងត្រូវបានរៀបចំដើម្បីគាំទ្រ និងតាមដានទៅលើដំណើរការការអនុវត្តការងារសង្គម។ ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន ក្រុមការងារទាំងអស់ចំណុះគណៈកម្មការត្រូវសហការរៀបចំតាក់តែងផែនការសកម្មភាព និងថវិការបស់ខ្លួន ដើម្បីជាមូលដ្ឋានក្នុងការរៀបចំ និងដាក់ចេញនូវផែនការសកម្មភាព និងថវិកា ដែលនឹងត្រូវអនុម័តដោយគណៈកម្មការ។

*ហានិភ័យ១.៣.១ ៖ ការប៉ាន់ប្រមាណថវិកាមិនបានច្បាស់លាស់ ឬខុសពីតម្លៃទីផ្សារជាក់ស្តែង ដែលនាំឱ្យខ្វះខាតថវិកាក្នុងអំឡុងពេលអនុវត្តសកម្មភាព ឬបង្ករជាឧបសគ្គដល់ការសម្រេចគោលដៅ។*

*គោលដៅទី២៖ ចាប់ផ្តើមដំណើរការការងាររបស់ក្រុមការងារនីមួយៗ និងអនុវត្តសកម្មភាពការងារស្របតាមផែនការសកម្មភាពដែលបានរៀបចំ។*

**សកម្មភាព ២.១.៖** បង្កើតមូលនិធិសម្រាប់ចំណាយអនុវត្តការងារសង្គមរបស់សិស្សមន្ត្រីជាន់ខ្ពស់ សម្រាប់ប្រមូល គ្រប់គ្រង និងចាត់ចែងការប្រើប្រាស់ថវិកាសម្រាប់ចំណាយនៅគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោង។

*ហានីភ័យ ២.១.១.៖ កង្វះតម្លាភាព ឬការគ្រប់គ្រងឯកសារចំណាយមិនបានត្រឹមត្រូវ (ខ្វះវិក្កយបត្រ ឬភស្តុតាងយោង) ដែលអាចបង្កឱ្យមានការភាន់ច្រឡំ ឬការបាត់បង់ទំនុកចិត្តក្នុងចំណោមសមាជិកក្រុមការងារ និងសាលា។*

**សកម្មភាព ២.២.៖** ក្រុមការងារបច្ចេកទេស ត្រូវដឹកនាំអនុវត្តការងារលើផ្នែកបច្ចេកទេសចាំបាច់លើការកំណត់ទីតាំងភូមិសាស្ត្រ និងទិន្នន័យលើផ្លាកលេខផ្ទះនិងផ្លូវ។

*ហានីភ័យ ២.២.១.៖ ការជួបប្រទះការលំបាកក្នុងការចូលទៅកាន់តំបន់គោលដៅមួយចំនួន ឬកង្វះកិច្ចសហការពីម្ចាស់ផ្ទះ ក្នុងការផ្តល់ព័ត៌មានជាក់លាក់ ដែលបណ្តាលឱ្យទិន្នន័យមានចន្លោះប្រហោង ឬមិនគ្រប់ជ្រុងជ្រោយ។*

**សកម្មភាព ២.៣.៖** រៀបចំបោះពុម្ពផ្លាកលេខផ្ទះ និងផ្លាកលេខផ្លូវ និងបង្គោលអំពូឡាលសូឡាបំភ្លឺផ្លូវ សម្រាប់ដាក់ជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។

*ហានីភ័យ ២.៣.១.៖ ការផលិតផ្លាកលេខផ្ទះ និងផ្លាកផ្លូវមានកំហុសបច្ចេកទេស (ខុសអក្ខរាវិរុទ្ធ ខុសពណ៌ ឬខុសទម្រង់ដែលបានកំណត់) ឬសម្ភារអំពូលសូឡាដែលបញ្ជាទិញមានគុណភាពទាបជាងស្តង់ដារដែលបានព្រមព្រៀង។*

*គោលដៅទី៣៖ ដាក់ឱ្យប្រជាពលរដ្ឋ និងអាជ្ញាធរនៅមូលដ្ឋានប្រើប្រាស់ជាផ្លូវការ និងបង្ហាញអំពីរបៀបប្រើប្រាស់ សារៈសំខាន់ និងតម្លៃនៃការដាក់ផ្លាកលេខផ្ទះ និងផ្លូវ។*

**សកម្មភាព ៣.១.៖** រៀបចំកម្មវិធីប្រគល់ និងសម្ពោធដាក់ឱ្យប្រើប្រាស់នូវសមិទ្ធផលដែលសម្រេចបានជូនអាជ្ញាធរ និងប្រជាពលរដ្ឋនៅមូលដ្ឋាន។

*ហានីភ័យ ៣.១.១.៖*

**សកម្មភាព ៣.២.៖** ធ្វើការបូកសរុប និងវាយតម្លៃទៅលើការចំណាយសរុបការដែលប្រើប្រាស់នៅក្នុងដំណើរការអនុវត្តគម្រោងការងារសង្គម។

*ហានីភ័យ ៣.២.១.៖ កត្តាអាកាសធាតុមិនអំណោយផល ឬការរៀបចំទីតាំង និងពិធីការមានការខ្វះខាត ដែលធ្វើឱ្យកម្មវិធីមិនអាចដំណើរការទៅតាមកាលវិភាគ ឬកាត់បន្ថយភាពអធិកអធមនៃពិធី។*

**សកម្មភាព ៣.៣.៖** ធ្វើការបូកសរុប និងវាយតម្លៃលើលទ្ធផលនៃដំណើរការការអនុវត្តគម្រោងការងារសង្គមទាំងមូល។

*ហានីភ័យ ៣.៣.១.៖ ការបាត់បង់ ឬការរក្សាទុកវិក្កយបត្រ និងឯកសារយោងមិនបានត្រឹមត្រូវក្នុងអំឡុងពេលអនុវត្តគម្រោង ដែលនាំឱ្យមានការលំបាកក្នុងការផ្ទៀងផ្ទាត់ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុបូកសរុបឱ្យមានតម្លាភាព។*

## ៣. ដំណើរការអនុវត្តគម្រោង

### ៣.១. ប្រភពថវិកា និងការប្រើប្រាស់អនុវត្តគម្រោង

ថវិកាសម្រាប់ការងារអនុវត្តគម្រោងនៃការរៀបចំធ្វើផ្លាកលេខផ្លូវ និងលេខផ្ទះ ជូនដល់ប្រជាពលរដ្ឋ តាមខ្នងផ្ទះ និងដងផ្លូវនេះ ចំនួន ២៨៦ផ្លាក ដោយចំណាយថវិកាសរុបចំនួន ៦ ០០០ ០០០ រៀល ដែលជា ថវិកាបានមកពីការបង់វិភាគទានរបស់សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១៣ នៃសាលាភូមិន្ទរដ្ឋបាល។

ដើម្បីជាការធានាលើការចំណាយថវិកាសម្រាប់ការអនុវត្តកិច្ចការគម្រោង និងមានភាពទុកចិត្តខ្ពស់ ពីសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១៣ នៃសាលាភូមិន្ទរដ្ឋបាលនោះ ក្រុមការងារបានប្រើប្រាស់ថវិកា ដែលមានដូចចំនួន ខាងលើ សម្រាប់យកទៅអនុវត្តតាមសកម្មភាពនីមួយៗ នៅក្នុងគោលដៅទាំងបី (៣) ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | ការប្រើប្រាស់ថវិកាសម្រាប់កិច្ចការអនុវត្តគម្រោង |
|---|---|---|
| I.គោលដៅទី១៖ ចាប់ផ្ដើមដំណើរការប្រើប្រាស់ថវិកាអស់ចំនួន 15% ស្មើនឹងចំនួន ៩០០,០០០ រៀល ដែលជាថវិកាទទួលបានពីវិភាគទានរបស់សិស្សមន្ត្រីជាន់ខ្ពស់ជំនានទី១៣នៃសាលាភូមិន្ទរដ្ឋបាល | | |
| ១ | សកម្មភាពទី១ | ប្រើប្រាស់អស់ថវិកាចំនួន ៣០០,០០០រៀល |
| ២ | សកម្មភាពទី២ | ប្រើប្រាស់អស់ថវិកាចំនួន ៣០០,០០០រៀល |
| ៣ | សកម្មភាពទី៣ | ប្រើប្រាស់អស់ថវិកាចំនួន ៣០០,០០០រៀល |
| II.គោលដៅទី២៖ ចាប់ផ្ដើមដំណើរការប្រើប្រាស់ថវិកាអស់ចំនួន ៦០% ស្មើនឹងចំនួន ៣,៦០០,០០០រៀល ដែលជាថវិកាទទួលបានពីវិភាគទានរបស់សិស្សមន្ត្រីជាន់ខ្ពស់ជំនានទី១៣នៃសាលាភូមិន្ទរដ្ឋបាល | | |
| ១ | សកម្មភាពទី១ | ប្រើប្រាស់អស់ថវិកាចំនួន ១,២០០,០០០រៀល |
| ២ | សកម្មភាពទី២ | ប្រើប្រាស់អស់ថវិកាចំនួន ១,២០០,០០០រៀល |
| ៣ | សកម្មភាពទី៣ | ប្រើប្រាស់អស់ថវិកាចំនួន ១,២០០,០០០រៀល |
| III.គោលដៅទី៣៖ ចាប់ផ្ដើមដំណើរការប្រើប្រាស់ថវិកាអស់ចំនួន ២៥% ស្មើនឹងចំនួន ១,៥០០,០០០ រៀលដែលជាថវិកាទទួលបានពីវិភាគទានរបស់សិស្សមន្ត្រីជាន់ខ្ពស់ជំនានទី១៣នៃសាលាភូមិន្ទរដ្ឋបាល | | |
| ១ | សកម្មភាពទី១ | ប្រើប្រាស់អស់ថវិកាចំនួន ១២,០០០,០០០រៀល |
| ២ | សកម្មភាពទី២ | ប្រើប្រាស់អស់ថវិកាចំនួន ១៥០,០០០រៀល |
| ៣ | សកម្មភាពទី៣ | ប្រើប្រាស់អស់ថវិកាចំនួន ១៥០,០០០រៀល |

### ៣.២. ការជ្រើសរើសធនធានមនុស្ស

ដើម្បីសម្រេចបាននូវគម្រោងខាងលើ ក្រុមការងារបានជ្រើសរើសអ្នកច្ចេកទេសជំនាញដាក់ផ្លាកលេខផ្លូវ និងលេខផ្ទះ ចំនួន០១រូប ក្រុមការងារដែលបានជ្រើសរើសចេញពីសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១៣ នៃសាលាភូមិន្ទរដ្ឋបាលចំនួន០៥រូប តំណាងអាជ្ញាធរមូលដ្ឋានចំនួន ០៤ និងប្រជាពលរដ្ឋ




ដើម្បីអនុវត្តគម្រោងនេះ និងបានបែងចែកជា ២ចំណុច សំខាន់ៗដូចខាងក្រោម៖

**៣.២.១ រចនាសម្ព័ន្ធការអនុវត្តគម្រោង**

**៣.២.២ តួនាទីភារៈកិច្ច និងការទទួលខុសត្រូវ**

**ក.ប្រធានគម្រោង**

លោក ហេង ស្រេង

- ជាប្រធានគម្រោង ទទួលបន្ទុកត្រួតពិនិត្យតាមដានរាល់កិច្ចការទូទៅ និងទទួលខុសត្រូវចំពោះការងារអនុវត្តគម្រោងទាំងមូល។

- ទទួលបន្ទុកដឹកនាំផ្ទាល់លើផ្នែកទាំងបួន ដើម្បីកៀរគរថវិកា និងសម្ភារៈ ពាក់ព័ន្ធគម្រោង និងធ្វើជាសេនាធិការជូនប្រធានគម្រោង។

**ខ-ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ**

លោក អ៊ាត ហង្សា

- ទទួលបន្ទុកទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធលើកិច្ចការទូទៅរបស់ គម្រោង និងរៀបចំរាល់ឯកសារលិខិតស្នាមដែលពាក់ព័ន្ធ នឹងគម្រោង ទាំងមូល។

- ទទួលបន្ទុកគ្រប់គ្រប់ថវិកាសម្រាប់ចំណូល និងចំណាយលើការងារ របស់គម្រោង និងលើប្រតិបត្តិការណ៍ផ្សេងពាក់ព័ន្ធ នឹងគម្រោង។

- ទទួលបន្ទុកធ្វើរបាយការណ៍ស្តីពីការចំណូល និងចំណាយសម្រាប់ការ អនុវត្តគម្រោងជូនប្រធានគម្រោង។

**គ-ផ្នែកបច្ចេកទេស**

លោក ហាត់ បូសើង

- ទទួលបន្ទុកទំនាក់ទំនងជាមួយអ្នកជំនាញបច្ចេកទេសដាក់ផ្លាកលេខ ផ្លូវ និងលេខផ្ទះ គម្រោងនិងមានភារកិច្ចគ្រប់គ្រងការដាក់ផ្លាកលេខផ្លូវ និងលេខផ្ទះ នូវតាមដងផ្លូវ និងខ្នងផ្ទះ។
- ទទួលបន្ទុកលើការសិក្សាកំណត់ទីតាំងសម្រាប់ដាក់ផ្លាកលេខផ្លូវ និង លេខផ្ទះ។
- ទទួលបន្ទុកគ្រប់គ្រងសម្ភារៈគម្រោងទាំងមូល។

**ឃ-ផ្នែកសម្របសម្រួល**

លោក សំ ស៊ីនួន

- ទទួលបន្ទុកសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ និង គ្រប់ភាគីពាក់ព័ន្ធ។
- ទទួលបន្ទុក សម្របសម្រួល និងសិក្សាអំពីផលប៉ះពាល់ ដើម្បីសងជា សំណងជូនប្រជាពលរដ្ឋ។
- ទទួលបន្ទុក សម្របសម្រួល និងធ្វើការដោះស្រាយរាល់បញ្ហាទូទៅ សម្រាប់ការរាំងស្ទះនៃដំណើរការគម្រោងទាំងមូល។
- ទទួលបន្ទុក សម្របសម្រួល និងសិក្សាអំពីផលប៉ះពាល់ ដើម្បីសងជា សំណងជូនប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធ។

**ង-ផ្នែកត្រួតពិនិត្យ និងវាយតម្លៃ**

លោក អ៊ូច វណ្ណថេត

- ទទួលបន្ទុក ត្រួតពិនិត្យរាល់សកម្មភាពការងាររបស់គម្រោង។
- ទទួលបន្ទុកតាមដាន និងតាមដានបន្តសម្រាប់គម្រោង ដើម្បីរាយការណ៍ ជូនប្រធានគម្រោង។
- ទទួលបន្ទុក វាយតម្លៃអំពីលទ្ធផលរបស់គម្រោងជូនប្រធានគម្រោង។
- ទទួលបន្ទុកតាមដាន និងតាមដានបន្តសម្រាប់គម្រោង ដើម្បីរាយការណ៍ ជូនប្រធានគម្រោង។

### ៣.៣. ការប្រើប្រាស់ផែនការពេលវេលា

គម្រោងនេះ ត្រូវប្រើប្រាស់ពេលវេលាសរុបចំនួន ៤ខែ គិតចាប់ពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៥ និងត្រូវបានលម្អិតតាមផែនការសកម្មភាពដូចខាងក្រោម៖

| ល.រ | សកម្មភាព | ឆ្នាំ២០២៥ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | កញ្ញា | | | | តុលា | | | | វិច្ឆិកា | | | | ធ្នូ | | | |
| | | សប្តាហ៍ទី១ | សប្តាហ៍ទី២ | សប្តាហ៍ទី៣ | សប្តាហ៍ទី៤ | សប្តាហ៍ទី១ | សប្តាហ៍ទី២ | សប្តាហ៍ទី៣ | សប្តាហ៍ទី៤ | សប្តាហ៍ទី1 | សប្តាហ៍ទី2 | សប្តាហ៍ទី៣ | សប្តាហ៍ទី៤ | សប្តាហ៍ទី1 | សប្តាហ៍ទី២ | សប្តាហ៍ទី៣ | សប្តាហ៍ទី៤ |
| I.គោលដៅទី១ | | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | សកម្មភាពទី១ | ■ | | | | | | | | | | | | | | | |
| ២ | សកម្មភាពទី២ | | ■ | | | | | | | | | | | | | | |
| ៣ | សកម្មភាពទី៣ | | ■ | ■ | | | | | | | | | | | | | |
| II.គោលដៅទី២ | | | | | | | | | | | | | | | | | |
| ១ | សកម្មភាពទី១ | | ■ | ■ | ■ | ■ | ■ | | | | | | | | | | |
| ២ | សកម្មភាពទី២ | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | |
| ៣ | សកម្មភាពទី៣ | | | | | | | | | ■ | ■ | ■ | ■ | | | | |
| III.គោលដៅទី៣ | | | | | | | | | | | | | | | | | |
| ១ | សកម្មភាពទី១ | | | | | | | | | | | ■ | ■ | ■ | | | |
| ២ | សកម្មភាពទី២ | | | | | | | | | | | | | ■ | ■ | ■ | |
| ៣ | សកម្មភាពទី៣ | | | | | | | | | | | | | | | ■ | ■ |

## ៣.៤. ការប្រើប្រាស់ធនធានរបស់គម្រោង

ក្រុមការងារបានប្រើប្រាស់នូវធនធានសម្រាប់គម្រោងខាងលើរួមមានដូចជា៖ មនុស្ស ថវិកា សម្ភារៈ ស្រប តាមពេលវេលា និងផែនការសកម្មភាពដែលបានគ្រោងទុក។

## ៣.៥. ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

### ៣.៥.១ ការតាមដានត្រួតពិនិត្យ

ដើម្បីឱ្យគម្រោងបញ្ចប់បានដោយជោគជ័យក្រុមការងារត្រូវធ្វើការប្រជុំតាមដាននូវសកម្មភាពការងារទៅតាមផ្នែកនិងដាក់ផែនការឱ្យផ្នែកនីមួយៗទទួលខុសត្រូវលើការងាររបស់ខ្លួន ដើម្បីកំណត់ឱ្យបានចំណុចខ្លាំង និងចំណុចខ្សោយរបស់គម្រោងក្នុងគោលបំណងឱ្យគម្រោង ឈានដល់ការទទួលបាន ជោគជ័យតាមផែនការរបស់គម្រោង។

### ៣.៥.២ ការវាយតម្លៃ

នៅពេលបញ្ចប់គម្រោង ក្រុមការងារត្រូវធ្វើការប្រជុំ វាយតម្លៃអំពីសកម្មភាព បញ្ហាប្រឈមនានា ដើម្បីធ្វើការសម្រេចចិត្តអំពីនិរន្តភាពគម្រោង សម្រាប់ ឱ្យក្រុមការងារធ្វើកំណត់ហេតុ ប្រគល់ និងទទួលការគ្រប់គ្រងគម្រោងបន្ត។

### ៣.៥.៣ ការតាមដានបន្ត

ក្រុមការងារត្រូវធ្វើការប្រជុំគ្រប់ភាគីពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានភូមិ សង្កាត់ ក្រុង និងប្រជាពលរដ្ឋ ដែលទទួលផល នៃការប្រើប្រាស់គម្រោង ការដាក់ផ្លាកលេខផ្លូវ និងលេខផ្ទះ ប្រគល់ជូនដល់អាជ្ញាធរមូលដ្ឋានគ្រប់គ្រងគម្រោងបន្ត ដើម្បីតាមដាន ថែរក្សាការពារគម្រោងឱ្យមាននិរន្តរភាព។ ក្រុមការងារនិងចូលរួមតាមដានអំពីស្ថានភាពគម្រោង តាមរយៈអាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ ឬចុះពិនិត្យផ្ទាល់។

## ៣.៦. ការបញ្ចប់គម្រោង

ដើម្បីឱ្យគម្រោងខាងលើអាចបញ្ចប់ទៅបានប្រកបដោយប្រសិទ្ធភាព និងអាចយកទៅប្រើប្រាស់បាន ក្រុមការងារត្រូវមានដូចជា គំនូសប្លង់កំណត់ទីតាំងភូមិសាស្ត្រច្បាស់លាស់ ធនធានមនុស្ស

ថវិកា សម្ភារៈ គ្រប់គ្រាន់ ដោយមានការសហការចូលរួមពីគ្រប់អាជ្ញាធរពាក់ព័ន្ធ ជាពិសេសការលះបង់ និងការចូលរួម យ៉ាងសំខាន់ពីប្រជាពលរដ្ឋក្នុងការរួមចំណែកអនុវត្តគម្រោងនេះ ទើបធ្វើឱ្យក្រុមការងារសម្រេចគម្រោង នេះបានដោយជោគជ័យ។

## ៤. ការវិភាគ SWOT នៅលើដំណើរការអនុវត្តគម្រោង

### ៤.១. ចំណុចខ្លាំង (Strengths)

- **ឆន្ទៈនយោបាយថ្នាក់ដឹកនាំកំពូលរបស់សាលាភូមិន្ទរដ្ឋបាល៖** តាមរយៈគោលនយោបាយសាលាលើការងារសង្គមជាកាតព្វកិច្ចចាំបាច់នៃការបណ្តុះបណ្តាល ហើយថ្នាក់ដឹកនាំកំពូលសាលាក៏ជាក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ បានបង្កើតជាបណ្តាញទំនាក់ទំនងទូលំទូលាយ (ខ្សែរយៈរដ្ឋបាល) ដែលបានបង្កលក្ខណៈងាយស្រួលដល់សិស្សមន្ត្រី ក្នុងការស្នើរសុំកិច្ចសហការពីអាជ្ញាធរមូលដ្ឋាន ដោយបានកាត់បន្ថយនូវភាពយឺតយ៉ាវនៃនីតិវិធីរដ្ឋបាលស្មុគស្មាញ និងបច្ចេកទេសពាក់ព័ន្ធ
- **ការគាំទ្រពីអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធគ្រប់កម្រិត៖** សហការ ផ្តល់ទិន្នន័យ ឯកសារពាក់ព័ន្ធ និងសម្របសម្រួលទាំងមុនពេល កំឡុងពេល និងបញ្ចប់គម្រោង រួមមានការសិក្សាប្រមូលទិន្នន័យជាក់ស្តែងតាមខ្នងផ្ទះ ផ្លូវ ការតម្លើង និងការសម្ភោធដាក់អោយប្រើប្រាស់ជាដើម
- **ធនធានមនុស្សគ្រប់គ្រាន់ ជាមួយនឹងរចនាសម្ព័ន្ធច្បាស់លាស់៖** ការដឹកនាំ គ្រប់គ្រង ចាត់ចែងគម្រោងបានធ្វើការបែងចែកភារកិច្ច និងការទទួលខុសត្រូវច្បាស់លាស់ ដូ. គណៈកម្មការកិច្ចការងារសង្គមរួមមាន លេខាធិការដ្ឋាន ក្រុមបច្ចេកទេសនិងរចនា ក្រុមផ្សព្វផ្សាយនិងទំនាក់ទំនងសាធារណៈ ក្រុមគណនេយ្យនិងហិរញ្ញវត្ថុ ក្រុមភស្តុភារនិងសម្ភារៈ ជាដើម
- **ការប្រើប្រាស់ចំណេះដឹងលើបច្ចេកវិទ្យាឌីជីថល៖** ដំណើរការអនុវត្តន៍ត្រូវបានធ្វើឡើងដោយមានការសិក្សាប្រមូលស្រង់ទិន្នន័យ ចងក្រងផែនទីឌីជីថលជាដើម ទាក់ទងទៅនឹងការរៀបចំកំណត់លេខផ្ទះ លេខផ្លូវ តាមលំដាប់លំដោយត្រឹមត្រូវតាមបច្ចេកទេសរដ្ឋបាល
- ក្រុមការងារមានការឯកភាពផ្ទៃក្នុង សហការ និងសាមគ្គីភាពខ្ពស់។

### ៤.២. ចំណុចខ្សោយ (Weaknesses)

- **ទីតាំងភូមិសាស្ត្រគម្រោង៖** ស្ថិតនៅឆ្ងាយពីសាលា ក្នុងការធ្វើដំណើរទៅអនុវត្តន៍គម្រោង
- **កត្តាពេលវេលា៖** ការចុះអនុវត្តន៍គម្រោងបានតែថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាក ក្រោយពីការសិក្សា អាចបណ្តាលអោយការអនុវត្តន៍ តាមដាន និងត្រួតពិនិត្យការងារមានកម្រិត
- **កម្រិតជំនាញបច្ចេកទេស៖** សិស្សមន្ត្រីមានសមត្ថភាពដឹកនាំ និងគ្រប់គ្រង ប៉ុន្តែអាចខ្វះជំនាញបច្ចេកទេសផ្ទាល់ក្នុងការដំឡើងផ្លាកលេខ បង្គោល ដែលអាចប៉ះពាល់ដល់គុណភាពដំឡើង
- **កញ្ចប់ថវិកាមានកំណត់៖** ដោយសារជាគម្រោងសង្គម ថវិកាគម្រោងទាំងមូលជាមូលនិធិរបស់សិស្សមន្ត្រីតែមួយប្រភពដែលអាចប៉ះពាល់ដល់ការជ្រើសរើសសម្ភារៈដែលមានគុណភាពខ្ពស់
- ការយល់ដឹងរបស់អាជ្ញាធរលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅមានកម្រិត

### ៤.៣. ឱកាស (Opportunities)

- **ការធ្វើទំនើបកម្មភូមិសាស្ត្ររដ្ឋបាលមូលដ្ឋាន៖** ការបំពាក់ផ្លាកលេខផ្ទះ ផ្លូវ បានផ្តល់ឱកាសដល់អាជ្ញាធរក្នុងការធ្វើបច្ចុប្បន្នភាពស្ថិតិប្រជាជន ផែនទីភូមិ និងជាមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំអត្តសញ្ញាណខ្នងផ្ទះ ផ្លូវ តាមបែបប្រព័ន្ធគ្រប់គ្រងទិន្នន័យឌីជីថល ដើម្បីសម្រួលដល់ការគ្រប់គ្រងរដ្ឋបាលទូទៅ និងការផ្តល់សេវាសង្គមកាន់តែល្អប្រសើរ
- **ការបង្កើតភាពជាគំរូ៖** ប្រសិនបើគម្រោងនេះទទួលបានជោគជ័យ វានឹងអាចត្រូវយកទៅអនុវត្តន៍នៅភូមិផ្សេងៗទៀត ក៏ដូចជាតាមបណ្តារខេត្តដ៏ទៃទៀត
- **ការគាំទ្រពីពលរដ្ឋ ឬបណ្តាវិស័យឯកជន៖** ប្រជាពលរដ្ឋក្នុងមូលដ្ឋានគម្រោងអាចចូលរួមជាកម្លាំងពលកម្ម ឬការថែទាំ ដែលពង្រឹងសាមគ្គីភាពរវាងរដ្ឋ និងប្រជាពលរដ្ឋ ព្រមទាំងអាចមានលទ្ធភាពទាក់ទាញការចូលរួមពីសប្បុរសជនពីវិស័យឯកជនក្នុងមូលដ្ឋាន។

### ៤.៤. បញ្ហាប្រឈម (Threats)

- ភាពយឺតយ៉ាវ ឬពន្យារពេលក្នុងការផ្គត់ផ្គង់សម្ភារៈ (ផ្លាកលេខផ្ទះ ផ្លូវ...) ពីអ្នកផ្គត់ផ្គង់សម្ភារៈ
- ការសហការពីអាជ្ញាធរ តាមនីតិវិធីបែបទម្លាប់ប្រពៃណី ឬគ្មានផែនការច្បាស់លាស់...
- **និរន្តរភាពនៃការថែទាំ៖** បញ្ហាប្រឈមធំបំផុតគឺការថែទាំក្រោយពេលបញ្ចប់គម្រោង ពោលគឺពុំមានផែនការថែទាំជាក់លាក់ពីអាជ្ញាធរបន្ទាប់ពីប្រគល់ជូនមូលដ្ឋានក្នុងការប្រើប្រាស់
- **ការយល់ដឹងរបស់សហគមន៍៖** ហានិភ័យនៃការបំផ្លិចបំផ្លាញ ឬការលួចសម្ភារៈ ប្រសិនបើប្រជាពលរដ្ឋមិនមានស្មារតីម្ចាស់ការ និងចូលរួមក្នុងការថែរក្សាទ្រព្យសម្បត្តិរដ្ឋ
- **កត្តាអាកាសធាតុ៖** ពន្យារពេលគម្រោង (ភ្លៀង ឬគ្រោះធម្មជាតិដ៏ទៃទៀត...)

## ៥. សេចក្តីសន្និដ្ឋាន

ជារួមមក លទ្ធផលនៃការអនុវត្តគម្រោងដំឡើងផ្លាកលេខផ្លូវចំនួន ១០ផ្លាក និងផ្លាកលេខផ្ទះចំនួន ២៨៦ផ្លាក នៅភូមិស្តុះ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺនេះ គឺជាសក្ខីភាពនៃការសម្រេចបាននូវការផ្សារភ្ជាប់យ៉ាងជិតស្និទ្ធរវាងចំណេះដឹងទ្រឹស្តីដែលយើងខ្ញុំទាំងអស់គ្នាជាសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១៣ នៃសាលាភូមិន្ទរដ្ឋបាល បានសិក្សាក្នុងថ្នាក់ ទៅនឹងការអនុវត្តការងារសង្គមជាក់ស្តែងនៅមូលដ្ឋាន។ តាមរយៈសកម្មភាពនេះ យើងខ្ញុំជាសិស្សមន្ត្រីមិនត្រឹមតែបានយល់ដឹងកាន់តែស៊ីជម្រៅអំពីកិច្ចការរដ្ឋបាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានពង្រឹងស្មារតីការងារជាក្រុមយ៉ាងរឹងមាំ និងបង្កើនសមត្ថភាពក្នុងការសម្របសម្រួល ក៏ដូចជាជំនាញទំនាក់ទំនង ជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដោយផ្ទាល់។ បទពិសោធន៍នៃការចុះអនុវត្តផ្ទាល់នេះ បានក្លាយជាមេរៀនដ៏មានតម្លៃក្នុងការបណ្តុះនូវក្រមសីលធម៌វិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងនាមជាមន្ត្រីសាធារណៈនាពេលអនាគតដែលត្រូវមានភាពបត់បែន និងសមត្ថភាពដោះស្រាយបញ្ហាប្រឈមនានានៅចំពោះមុខ។

ទន្ទឹមនឹងការអភិវឌ្ឍសមត្ថភាពរបស់យើងខ្ញុំទាំងអស់គ្នាជាសិស្សមន្ត្រី គម្រោងនេះក៏បានក្លាយជាឧបករណ៍ដ៏មានសារៈសំខាន់ក្នុងការធ្វើទំនើបកម្មរដ្ឋបាលក្រុងច្បារមន ឱ្យកាន់តែមានប្រសិទ្ធភាព និងតម្លាភាព។ ការរៀបចំប្រព័ន្ធអាសយដ្ឋានឱ្យមានលក្ខណៈស្តង់ដារបែបនេះ មិនត្រឹមតែជួយសម្រួលដល់ការគ្រប់គ្រងទិន្នន័យស្ថិតិប្រជាពលរដ្ឋតាមខ្នងផ្ទះឱ្យបានច្បាស់លាស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាកត្តាគន្លឹះក្នុងការលើកកម្ពស់គុណភាពសេវាសាធារណៈ ដូចជាការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត និងសេវាអនាម័យ។ ជាពិសេស វានឹងបង្កលក្ខណៈងាយស្រួលដល់ភ្នាក់ងារសង្គ្រោះបន្ទាន់ ដូចជារថយន្តពន្លត់អគ្គិភ័យ និងរថយន្តសង្គ្រោះ ក្នុងការស្វែងរកគោលដៅបានចំទីតាំង និងទាន់ពេលវេលា ដែលជាការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពចំពោះតម្រូវការចាំបាច់ និងការធានាសុវត្ថិភាពជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

លើសពីកិច្ចការរដ្ឋបាល និងសេវាសង្គម ការរៀបចំផ្លាកលេខផ្លូវ និងលេខផ្ទះនេះ ក៏ជាផ្នែកមួយមិនអាចខ្វះបានក្នុងការជំរុញសកម្មភាពសេដ្ឋកិច្ច និងសណ្តាប់ធ្នាប់សាធារណៈឱ្យកាន់តែរឹងមាំ។ តាមរយៈប្រព័ន្ធសម្គាល់ទីតាំងដែលច្បាស់លាស់ វានឹងផ្តល់ភាពងាយស្រួលដល់ការធ្វើធុរកិច្ច ការដឹកជញ្ជូនទំនិញ និងសេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលកំពុងមានសន្ទុះខ្លាំងក្នុងពេលបច្ចុប្បន្ន ព្រមទាំងជួយដល់អាជ្ញាធរក្នុងការគ្រប់គ្រងការប្រមូលពន្ធអចលនទ្រព្យ និងការបែងចែកសេវាកម្មរដ្ឋបាលឱ្យកាន់តែមានសមធម៌។ បន្ថែមលើនេះ គម្រោងនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់សោភ័ណភាពទីក្រុងឱ្យស្របតាមបទដ្ឋានអភិវឌ្ឍន៍ទីក្រុងឆ្លាតវៃ ដែលឆ្លុះបញ្ចាំងពីភាពស៊ីវិល័យនៃសង្គម។ ជារួម លទ្ធផលនៃគម្រោងនេះគឺជាគ្រឹះដ៏រឹងមាំសម្រាប់រដ្ឋបាលក្រុងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការកសាងសហគមន៍ឱ្យមានការរីកចម្រើនប្រកបដោយបរិយាបន្ន និងចីរភាពយូរអង្វែង។